ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣

ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល
(ខេមបូឌា) ភីអិលស៊ី

រាជធានីភ្នំពេញថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
# ស្តីពីការបែងចែកភាគលាភជូនភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោត របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល(ខេមបូឌា)ភីអិលស៊ី

ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (ក្រុមហ៊ុន "ហ្គ្រេន ធ្វីន") មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតរបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន ទាំងអស់មេត្តាជ្រាបថាៈ ក្រុមហ៊ុន ហ្គ្រេន ធ្វីន នឹងបែងចែកភាគលាភ ជូនភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតរបស់ក្រុមហ៊ុនដូចខាងក្រោមៈ

| | | |
|---|---|---|
| ១-ប្រភេទភាគលាភដែលបែងចែក | : | ជាសាច់ប្រាក់ |
| ២-រយៈពេលភាគលាភ | : | ប្រចាំឆ្នាំ២០១៦ |
| ៣-អនុបាតនៃការសងភាគលាភ | : | ១៨,៩០%នៃចំណេញក្រោយបង់ពន្ធឆ្នាំ២០១៦ |
| ៤-ភាគលាភសរុបដែលបែងចែក | : | ៤.០០០.០០០.០០០ រៀល |
| ៥-ភាគលាភក្នុងមួយឯកតាមូលបត្រមកម្មសិទ្ធ | : | ១០០ រៀល |
| ៦-កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកត្រូវទទួលបានភាគលាភ | : | ថ្ងៃទី ០៧ ខែកក្កដា ២០១៧ |
| ៧-ការបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ | : | ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០១៧ |

<u>បញ្ជាក់ៈ</u>

១- ភាគហ៊ុនិកដែលមានសិទ្ធទទួលបានភាគលាភ ដូចបានកំណត់ខាងលើនេះ ជាភាគហ៊ុននិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិកផ្លូវការ ដែលទទួលបានពីបញ្ជីភាគហ៊ុនិកបណ្តោះអាសន្ន ដែលរៀបចំឡើងនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ ២០១៧

២- ភាគហ៊ុនិកដែលលក់មូលបត្រកម្មសិទ្ធរបស់ខ្លួន នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០១៧ នៅតែមានសិទ្ធទទួលបាននូវភាគលាភដដែល។

៣- ភាគហ៊ុនិកដែលទិញមូលបត្រកម្មសិទ្ធរបស់ក្រុមហ៊ុន នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧ នឹងមិនមានសិទ្ធទទួលបានភាគលាភ ដូចបានកំណត់ខាងលើនោះទេ។

៤- ការទូទាត់ភាគលាភ ចាប់ផ្តើមពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៧ ដល់ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ២០១៧ នៅរៀងរាល់ថ្ងៃធ្វើការ។ ក្នុងករណី មានភាពមិនត្រឹមត្រូវ ក្នុងការទូទាត់ភាគលាភខាងលើ ភាគហ៊ុនិក អាចធ្វើការតវ៉ាចាប់ពី ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ដល់ ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ នៅរៀងរាល់ថ្ងៃធ្វើការ។

ព័ត៌មានបន្ថែមសូមទាក់ទងទៅកាន់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រនិងភ្នាក់ងារទូទាត់របស់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដូចខាងក្រោម៖

- អាសយដ្ឋាន :អាគារលេខ៦១មហាវិថីព្រះមុនីវង្សសង្កាត់ស្រះចក ខណ្ឌដូនពេញរាជធានីភ្នំពេញ
- ទូរសព្ទ: (៨៥៥)២៣-៩៩៨ ៧៧៧ (ភ្ជាប់ទៅ: ៨៣១៦៧)
- ទូរសារ: (៨៥៥)១៥ ៦០០ ៧៤៣
- ទូរសព្ទដៃ: (៨៥៥)១៥-៦០០ ៧៤៣
- អ៊ីម៉ែល: lim.an@acledabank.com.kh

**ក្រុមហ៊ុនហ្គ្រេន ធ្វីន អ៊ិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី**